## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារអាជ្ញាប័ណ្ណលេខ ១០៣ ឯអ

# អាជ្ញាប័ណ្ណរួមសំរាប់ លោក ញ៉ៀម ផាន្នី

# អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមមាត្រា ៧ និង ២៩ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- យោងសេចក្តីសំរេចរបស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានីភ្នំពេញ លេខ ០០២ សស.ថព ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១
- យោងតាមពាក្យស្នើសុំអាជ្ញាប័ណ្ណរួមរបស់លោក ញ៉ៀម ផាន្នី ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៤
- យោងតាមការពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណ ស្ថាប័នពាក់ព័ន្ធ និងសាធារណជន ចាប់ពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤
- យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី៤១ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៤

## សំរេច

### ប្រការ១

ផ្តល់**អាជ្ញាប័ណ្ណរួម** ជូនលោក **ញ៉ៀម ផាន្នី** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ** ") ភេទប្រុស ជនជាតិខ្មែរ ឆ្នាំកំណើត ១៩៧០ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ១៩២អា ភូមិបាក់ខែង សង្កាត់ព្រែកលាប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០១០៤៩២៤២៣ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៣ ដែលជាសេវាករកំពុងធ្វើសេវាកម្មអគ្គិសនីនៅភូមិបាក់ខែង សង្កាត់ព្រែកលាប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល សំរាប់ផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណ ដូចខាងក្រោម :

(ក) បន្តធ្វើសេវាកម្មផលិតកម្មអគ្គិសនីនៅភូមិបាក់ខែង សង្កាត់ព្រែកលាប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដើម្បីផ្គត់ផ្គង់អគ្គិសនីឱ្យប្រព័ន្ធចែកចាយរបស់ខ្លួនតាមធ្យោបាយផលិតកម្ម ដែលកំណត់ក្នុងឧបសម្ព័ន្ធទី២ ក្នុងរយៈពេលដែលកំណត់ដោយប្រការ៣ផ្នែកទី១ខាងក្រោម ដោយត្រូវគោរពតាមល័ក្ខខ័ណ្ឌនានា ដែលមានចែងក្នុងផ្នែកទី២ នៃអាជ្ញាប័ណ្ណនេះ ។

(ខ) បន្តធ្វើសេវាកម្មចែកចាយ និងលក់អគ្គិសនីឱ្យអ្នកប្រើប្រាស់ក្នុងតំបន់ចែកចាយដែលកំណត់ក្នុង ឧបសម្ព័ន្ធទី១ ផ្នែកទី២របស់អាជ្ញាប័ណ្ណនេះ ក្នុងរយៈពេលដែលកំណត់ដោយប្រការ៣ ផ្នែកទី១ ខាងក្រោមដោយត្រូវគោរពតាមល័ក្ខខ័ណ្ឌនានា ដែលមានចែងក្នុងផ្នែកទី២នៃអាជ្ញាប័ណ្ណនេះ។

**ប្រការ២**

ល័ក្ខខ័ណ្ឌនានារបស់អាជ្ញាប័ណ្ណនេះអាចកែសំរួល ឬធ្វើវិសោធនកម្មបានអនុលោមតាមបញ្ញត្តិរបស់អាជ្ញា ប័ណ្ណនេះ ឬតាមមាត្រា៧ និង៤៤ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។ អាជ្ញាប័ណ្ណដែល ផ្តល់ឱ្យនេះអាចដកហូតបានស្របតាមល័ក្ខខ័ណ្ឌដែលកំណត់ក្នុង ឧបសម្ព័ន្ធទី៣ផ្នែកទី២របស់អាជ្ញាប័ណ្ណ។

**ប្រការ៣**

អាជ្ញាប័ណ្ណនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ និងមានអាណត្តិចំនួន ២ឆ្នាំ និងអាចសុំបន្តទៀតឬស្នើសុំកែសំរួលបាន លើកលែងតែត្រូវបានដកហូតដោយអនុលោមតាមល័ក្ខខ័ណ្ឌ នៃអាជ្ញាប័ណ្ណនេះ។

ភ្នំពេញ, ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៤

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្ដីសម្រេចកែសម្រួលលើកទី១
# លើអាជ្ញាប័ណ្ណរូមលេខ ១០៣ ឯអ ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០៤
# សម្រាប់លោក ញ៉ៀម ផាន្នី

## អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណលេខ១០៣ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានចេញឱ្យលោក **ញ៉ៀម ផាន្នី** នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៤

-យោងពាក្យស្នើសុំបន្តអាណត្តិអាជ្ញាប័ណ្ណរបស់លោក **ញ៉ៀម ផាន្នី** ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៦ ដល់ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៦

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ៨៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦

## សម្រេច

**ប្រការ១**

ដោយផ្អែកលើសកម្មភាពរបស់លោក ញ៉ៀម ផាន្នី បានធ្វើការកែលម្អមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់ខ្លួនបានមួយចំនួនហើយតម្រូវឱ្យលោក ញ៉ៀម ផាន្នី ធ្វើការកែលម្អច្រើនបន្ថែមទៀតនៅឆ្នាំបន្តបន្ទាប់ ដើម្បីឱ្យស្របតាមល័ក្ខខ័ណ្ឌទូទៅនៃស្តង់ដាបច្ចេកទេសក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចកែសម្រួលអាជ្ញាប័ណ្ណរូមលេខ ១០៣ឯអ ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៤ ដែលបានផ្តល់ជូនលោក ញ៉ៀម ផាន្នី ដោយបន្តផ្តល់អាណត្តិអាជ្ញាប័ណ្ណចំនួន **០៣(បី) ឆ្នាំ** បន្តទៀត ។

**ប្រការ២**

អាណត្តិអាជ្ញាប័ណ្ណនេះ មានរយៈពេល ០៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៦ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួល លើកលែងតែត្រូវដកហូត ដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។

**ប្រការ៣**

សេចក្ដីសម្រេចនេះ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ១០៣ ឯអ ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ១០៣ ឯអ នឹងខ្លឹមសារ ដែលបានកែសម្រួលរួចហើយ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្ដីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវធ្វើសេចក្ដីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដូចតម្កល់ទុកឯកសារអាជ្ញាប័ណ្ណលេខ ១០៣ ឯអ ពីលើកមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ១០៣ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្ដីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

## ឧបសម្ព័ន្ធទី១
## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី

១- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី ដែលអ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិផ្តល់សេវាចែកចាយ និងផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ គឺនៅភូមិបាក់ខែង សង្កាត់ព្រែកលាប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ។

២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ "ផែនទីកំណត់ព្រំ ប្រទល់ " ដែលភ្ជាប់មកជាមួយ ។

៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណ មានបំណងស្នើសុំពង្រីក ឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា តាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្តីសំរេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម័ន្ធទី១នេះត្រូវធ្វើការកែសំរួល ដោយភ្ជាប់ជាមួយសេចក្តីសំរេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។

## ឧបសម្ព័ន្ធទី២
## មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ

### ក-មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ

### រោងម៉ាស៊ីន

១- ទីតាំងរោងម៉ាស៊ីនភ្លើងរបស់អ្នកកាន់អាជ្ញាប័ណ្ណ ស្ថិតក្នុងនៅភូមិបាក់ខែង សង្កាត់ព្រែកលាប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

### លក្ខណៈទូទៅនៃម៉ាស៊ីន

១- អ្នកកាន់អាជ្ញាប័ណ្ណមានម៉ាស៊ីនភ្លើងចំនួន ០១គ្រឿង ដែលមានអានុភាព តំឡើង ១០០ kVA ។

២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងឌៀស៊ែល ។

### លក្ខខ័ណ្ឌក្នុងការផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម

១- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណ មានបំណងស្នើសុំផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែល អាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសំរេចអនុញ្ញាតឱ្យផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម ឧបសម័ន្ធទី២នេះត្រូវធ្វើការកែសំរួល ដោយភ្ជាប់ជាមួយសេចក្តីសំរេចឱ្យផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្មនោះ ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិការ ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។